# សន្ទរកថា

## ឯកឧត្តម ស៊ីន នីនី

## អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គ

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី*

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយជាអនេកប្បការ ដែលបានមកចូលរួមសិក្ខាសាលាស្តីពី "ការពិភាក្សាបញ្ចប់អនុស្សារណៈយោគយល់គ្នាសំរាប់ការចែករំលែកទិន្នន័យ-ព័ត៌មានដើម្បីកិច្ចសហប្រតិបត្តិការ និងសហការរវាងអ្នកពាក់ព័ន្ធ"។ សិក្ខាសាលាថ្ងៃនេះមានសារៈសំខាន់សំរាប់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកពាក់ព័ន្ធទាំងអស់ដែលធ្វើការទាក់ទងនឹងតំបន់បឹងទន្លេសាប និងគំរោងជាច្រើនដែលកំពុងប្រតិបត្តិក្នុងតំបន់នេះ។

ក្នុងនាមគណៈកម្មាធិការជាតិទន្លេមេគង្គ និងក្នុងនាមខ្ញុំផ្ទាល់ សូមកោតសរសើរ និងវាយតំលៃខ្ពស់ចំពោះការចំណាយពេលដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដើម្បីចូលរួមសិក្ខាសាលាថ្ងៃនេះ ដែលជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចសហប្រតិបត្តិការ និងសហការ ក្នុងទិសដៅលើកស្ទួយគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងបរិស្ថានតំបន់បឹងទន្លេសាបប្រកបដោយចិរភាព ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី*

យើងបាន និងកំពុងធ្វើការងារទាក់ទងនឹងតំបន់ទន្លេសាប ជាមួយគំរោងជាច្រើន សំដៅលើកស្ទួយជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រក្នុងតំបន់នេះ។ ដើម្បីដោះស្រាយចំណោទ និងបញ្ហាទាំងនេះបាន យើងត្រូវមានទិន្នន័យបច្ចុប្បន្នភាព ត្រឹមត្រូវ និងអាចទុកចិត្តបាន ដែលអាចជូនដំណឹងដល់ថ្នាក់ដឹកនាំគ្រប់កំរិតធ្វើសេចក្តីសំរេច។ ការរៀបចំគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងការអនុវត្តន៍ប្រកបដោយសក្តានុភាព តម្រូវឱ្យមានទិន្នន័យពាក់ព័ន្ធ។ ក្នុងន័យនេះយើងបានបង្កើតប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថានបឹងទន្លេសាបនៅក្នុងលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីជ្រាបស្រាប់ហើយ ទោះបីជាមានទិន្នន័យច្រើនវិស័យសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ឬសម្រាប់ការធ្វើសេចក្តីសម្រេចក៏ដោយ ក៏យើងនៅតែត្រូវការទិន្នន័យបច្ចុប្បន្នភាព និងទៅតាមទម្រង់ត្រឹមត្រូវជាក់លាក់ថែមទៀតដែរ។ នេះមិនមែនមានន័យថាយើងមិនអាចរក

ទិន្នន័យទាំងនោះបាននោះទេ តែវាគ្រាន់តែមិនអាចរកបានទៅតាមទម្រង់ជាក់លាក់មួយដែលយើងចង់បាន មិនអាចរកបានពីអ្នកផលិតផ្ទាល់ និងទិន្នន័យមិនមានបច្ចុប្បន្នភាព។

ជាគំនិតផ្តួចផ្តើមតាមរយៈសិក្ខាសាលាមួយដែលបានរៀបចំនៅខេត្តសៀមរាបកាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ កន្លងមក ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនានា រួមទាំង មន្ត្រីក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក្នុងនោះក៏មាន ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលមានវត្តមាននៅទីនេះ ក៏បានចូលរួមផងដែរ បានផ្តល់ជាអនុសាសន៍មួយក្នុងការចែករំលែកទិន្នន័យ-ព័ត៌មានឱ្យមានតម្លាភាព ចាំបាច់ត្រូវមានអនុស្សារណៈយោគយល់គ្នាមួយទៅលើការផ្លាស់ប្តូរទិន្នន័យ-ព័ត៌មាន។ ទោះជាមានការលើកឡើងខ្លះថាតើអនុស្សារណៈគួរអនុវត្តដោយរបៀបណា ក៏មានការឯកភាពទទួលស្គាល់ថា អនុស្សារណៈនេះមានសារៈសំខាន់ ដែលធានាការឯកភាពគ្នាដោយធ្វើការសម្រេចប្រកបដោយប្រសិទ្ធភាព និងកសាងចំណេះដឹងជាមូលដ្ឋានដោយផ្អែកលើអ្វីដែលមានស្រាប់។

សិក្ខាសាលានេះផ្តល់ឱកាសល្អមួយដល់យើងទាំងអស់គ្នាមកពីស្ថាប័នផ្សេងៗ និងដែលតំណាងឱ្យក្រុមពាក់ព័ន្ធ និងចំណាប់អារម្មណ៍ដើម្បីសហការជាមួយគ្នា។ យើងទាំងអស់គ្នាគឺជាអ្នកផលិតផង និងជាអ្នកប្រើប្រាស់ទិន្នន័យផង។ ទិន្នន័យដែលបានផលិតដោយស្ថាប័នមួយតែងតែមានតម្លៃសំរាប់ការប្រើប្រាស់របស់ស្ថាប័នផ្សេងទៀត។ ដូច្នេះបើតួនាទីទាំងពីររបស់យើងនេះមានតុល្យភាពទៅវិញទៅមក នោះយើងទាំងអស់គ្នានឹងទទួលបានផលប្រយោជន៍ដូចគ្នា។ បើយើងចែករំលែកទិន្នន័យនេះដោយមិនគិតថ្លៃ និងដោយសុឆន្ទៈ នោះមានន័យថា យើងលើកទឹកចិត្តឱ្យអ្នកដទៃឱ្យធ្វើដូច្នេះដែរ។ ហើយក្នុងការផ្លាស់ប្តូរនេះ យើងទាំងអស់គ្នាគឺជាអ្នកទទួលបានផលប្រយោជន៍។ លទ្ធភាពដែលអាចទទួលបានទិន្នន័យត្រឹមត្រូវ និងតាមលំដាប់ អាចធ្វើឱ្យការងារយើងមានភាពងាយស្រួល និងមានខ្លឹមសារព្រោះថាថ្នាក់ដឹកនាំយើងនឹងផ្តោតការយកចិត្តទុកដាក់តែទៅលើការងារវិភាគទិន្នន័យជាជាងចំណាយពេលវេលានិងការប្រឹងប្រែងរបស់គាត់ក្នុងការប្រមូលទិន្នន័យ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ*

សព្វថ្ងៃមានប្រទេសជាង៦០ បានបង្កើតយន្តការផ្លាស់ប្តូរព័ត៌មាន **(Clearing House Mechanisms - CHMs)** នេះ ដើម្បីចែករំលែកព័ត៌មាន និងផ្សព្វផ្សាយវិស័យបរិស្ថាន។ យើងត្រូវធានាថា កម្ពុជាមិនចិតនៅក្រោយគេនោះឡើយចំពោះគំនិតផ្តួចផ្តើមរបស់ពិភពលោកនេះ។ យន្តការមួយដែលត្រូវបានប្រើប្រាស់ដើម្បីជំរុញអនុវត្តការងារទៅជាអចិន្ត្រៃយ៍នោះគឺ ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងភាគីពាក់-ព័ន្ធ ដើម្បីឱ្យតួនាទី និងការទទួលខុសត្រូវ អនុវត្ត ឯកភាព និងយោគយល់គ្នាទាំងសងខាង។

សំណើពង្រាងនៃអនុស្សារណៈយោគយល់គ្នា ទាំងភាសាអង់គ្លេស និងជាភាសាខ្មែរត្រូវបានចែកជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី មុនជាស្រេច។ ហើយអនុស្សារណៈយោគយល់គ្នានេះ ធានាថា ឯកឧត្តម លោកជំទាវ លោក លោកស្រី មានសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យទៅលើ ទិន្នន័យ និងព័ត៌មានដែលត្រូវបានចែករំលែក។ ឯកឧត្តម លោកជំទាវ លោក លោកស្រី ត្រូវធ្វើការសម្រេចថា តើទិន្នន័យដែលចែករំលែកមួយណាដែលមិនគិតថ្លៃ និងទិន្នន័យណាដែលមានកម្រិតអាចចែករំលែកបានតែក្នុងចំណោមអ្នករួមការងារមានវិជ្ជាជីវៈដូចគ្នាក្នុងក្រសួង និងស្ថាប័ន និងតើទិន្នន័យមួយណាដែលសម្ងាត់ ហើយដែលអាចចែករំលែកបានតែក្នុងលក្ខខណ្ឌ និងគោលការណ៍កំណត់ណានោះ។ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៅតែជាម្ចាស់ទិន្នន័យ និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្រើប្រាស់ និងចាត់ចែងវាតាមបំណងរបស់ខ្លួនដដែល។

អាស្រ័យហេតុនេះ ខ្ញុំសំណូមពរឯកឧត្តម លោកជំទាវ លោក លោកស្រីចូលរួមពិភាក្សាបញ្ហា កង្វល់ និងការយល់ឃើញក្នុងសិក្ខាសាលានេះ ដើម្បីជួយជំរុញដំណើរការកិច្ចសហការជាដៃគូរបស់យើងអាចឈានទៅមុខយ៉ាងឆាប់រហ័សបានក្នុងការចុះហត្ថលេខាលើអនុស្សារណៈដែលចាំបាច់នេះ។

យើងទាំងអស់គ្នាគួរងាកមករកអ្វីដែលជាផលប្រយោជន៍ជាធំ ជាជាងគិតគូពីអ្វីដែលជាឧបស័គ្គបន្តិចបន្តួចមាននៅតាមស្ថាប័ន និងក្រសួងនិមួយៗ។ ក្នុងន័យនេះ ខ្ញុំសូមស្វាគមន៍ និងថ្លែងអំណរគុណចំពោះវត្តមានចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ក្នុងសិក្ខាសាលានាថ្ងៃនេះ។

*ខ្ញុំសូមប្រកាសបើកសិក្ខាសាលាចាប់ពីពេលនេះតទៅ។*

*សូមអរគុណ*